ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:...១១...សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការចាត់តាំងបន្ថែមសមាសភាព នៃគណៈកម្មការអន្តរក្រសួង ដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីជូនដំណឹងលេខ ១១៥៦ សជណ.ពហ ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

-យោងសេចក្តីសម្រេចលេខ ១២៥ សសរ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។

-យោងតាមការចាំបាច់

## សម្រេច

**ប្រការ ១ ៖** ត្រូវបានចាត់តាំង ឯកឧត្តម វ៉ាន សំអឿន ជាសមាជិក នៃគណៈកម្មការអន្តរក្រសួង ដើម្បី ត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច។

**ប្រការ ២៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ
រាល់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
ដូចប្រការ ២
រាជកិច្ច
ឯកសារ កាលប្បវត្តិ